# I- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ ២០ អនក្រ.បក

ស្តីពី

ការធ្វើវិសោធនកម្ម លើអនុក្រឹត្យលេខ ៧៨ អនក្រ ចុះថ្ងៃទី ២៣

ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការ

ដឹកនាំការងារ នៃកម្មវិធីសិលា

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-អនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ៧៨អនក្រ ចុះថ្ងៃទី២៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

**សំរេច**

**មាត្រា ១ .-**

មាត្រា៣ ( ស្តីពីសមាសភាពគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ) នៃអនុក្រឹត្យ លេខ ៧៨ អនក្រ ចុះថ្ងៃទី២៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការ ដឹកនាំការងារ នៃកម្មវិធី សិលា ត្រូវបានកែប្រែដូចខាងក្រោមនេះ ៖

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួង ធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣-រដ្ឋលេខាធិការក្រសួង អភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៤-រដ្ឋលេខាធិការក្រសួង ផែនការ | សមាជិក |

www.pheakdeylaw.com

៥-អនុរដ្ឋលេខាធិការក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៦-អនុរដ្ឋលេខាធិការក្រសួង កិច្ចការនារី និងអតីតយុទ្ធជន សមាជិក

៧-អគ្គនាយករដ្ឋបាលរតនាគារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៨-អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាអគ្គលេខាធិការ

នៃគណៈកម្មាធិការទីតីសម្រួល និងអភិវឌ្ឍន៍ អគ្គលេខាធិការ

**មាត្រា ២.-**

រាល់បទបញ្ញត្តិណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងសមាជិកដូចមានចែងក្នុងមាត្រា១ និងអភិបាលខេត្ត-ក្រុង ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

ហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ប្រធានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិរីណា

★★★

## អនុក្រឹត្យ ២១ អនក្រ.បក

## ស្ដីពី ការបង្កើតគណៈកម្មាធិការជាតិទាំង ៦

## សំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ

## (Functional Cooperation)

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com